ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ១៩០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៧

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៨/ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៩ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ ឆ្នាំ២០០៧ ។

**សម្រេច :**

ប្រការ១.- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ត្រូវប្រមូលចាប់ពីថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ។

ប្រការ២.- ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំង បង្ហាញ និង ប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៦ ដើម្បីជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូននិងយានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ រួចហើយ ។

ប្រការ៣.- ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាពុំមានបង្កាន់ដៃពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ ២០០៦ ទេនោះ ត្រូវបង់ប្រាក់ពន្ធសំរាប់ឆ្នាំ ២០០៦ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ។

ប្រការ៤.- ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសំរាប់ឆ្នាំ ២០០៦ ម្ចាស់ មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសំរាប់ឆ្នាំ ២០០៦ រួចហើយ ដែលចេញ ដោយប្រធានសាខាពន្ធដារខេត្ត-ក្រុងនៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ ២០០៦ ។

ប្រការ៥.- ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

ប្រការ៦.- ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះនេះត្រូវបានលើកលែងចំពោះ :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យ របស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ប្រការ៧.- ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួល បង្កាន់ដៃបង់ពន្ធមួយសន្លឹក និងប័ណ្ណសំគាល់មួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗនោះ ។

បង្កាន់ដៃបង់ពន្ធនេះមានបិទត្រាដាសកណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូប ហង្សត្រួតពីលើ និងមានពន្លឺប្រាំពីរពណ៌ ដោយឡែកសំរាប់បង្កាន់ដៃបង់ពន្ធលើរថយន្ត មានបន្ថែមអក្សរ សហ៍ និងមាន សរសេរចំនួនប្រាក់ពន្ធ ៨០.០០០រៀល ១០០.០០០រៀល ១៥០.០០០រៀល ១៨០.០០០រៀល ២០០.០០០រៀល ២៥០.០០០រៀល ៤៥០.០០០រៀល ៦០០.០០០រៀល ៧៥០.០៨០រៀល ៨០០.០០០រៀល ១.០០០.០០០រៀល នៅពីក្រោម។ បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាទុកកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច

និងទុកជាឯកសារសំរាប់បង់ពន្ធឆ្នាំ ២០០៨ ។

ប្រការ៨.- សំរាប់ឆ្នាំ ២០០៧ ប័ណ្ណសំគាល់ដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទមានរូបភាព និង លក្ខណៈសំគាល់ដូចខាងក្រោម :

**១.ប័ណ្ណរាងរង្វង់មូល :**

នៅខាងលើបំផុតនៃប័ណ្ណមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។ នៅកណ្តាលមានលេខ "២០០៧" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធរថយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៧" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធរថយន្ត" មានសរសេរចំនួនប្រាក់ពន្ធ។ ខាងក្រោមចំនួនប្រាក់ពន្ធ មានសរសេរលេខរៀងនៃប័ណ្ណនីមួយៗ ។ នៅផ្នែកខាងមុខប័ណ្ណ មានបិទក្រដាស ពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និងមានពន្លឺប្រាំពីរពណ៌ ដោយឡែកសំរាប់រថយន្តមានបន្ថែមអក្សរ សហវ និង មានសរសេរចំនួនប្រាក់ពន្ធពី ៨០.០០០រៀល ដល់ ១.០០០.០០០រៀល។

ប័ណ្ណរាងរង្វង់មូលនេះមាន ១២ ពណ៌គឺ :

- **ប័ណ្ណពណ៌ត្រួយចេក** ប្រើសំរាប់ :
  - + ត្រាក់ទ័រមានកម្លាំង ៣៥ សេះ
  - + ត្រាក់ទ័រមានកម្លាំង ៦៥ សេះ
  - + ត្រាក់ទ័រមានកម្លាំង ៨២ សេះ
- **ប័ណ្ណពណ៌ផ្កាឈូក** ប្រើសំរាប់ :
  - + រថយន្តទេសចរណ៍កម្លាំងដល់ ៩ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- **ប័ណ្ណពណ៌ទឹកប៊ិច** ប្រើសំរាប់ :
  - + រថយន្តទេសចរណ៍កម្លាំង ៩ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
  - + រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតលើស ៥ ឆ្នាំ
- **ប័ណ្ណពណ៌លឿងខ្ចី** ប្រើសំរាប់ :
  - + រថយន្តដឹកទំនិញដល់ ៣ តោន
  - + រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  - + រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
- **ប័ណ្ណពណ៌បៃតង** ប្រើសំរាប់ :
  - + រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេះ ដល់ ១៧ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- **ប័ណ្ណពណ៌ផ្ទៃមេឃ** ប្រើសំរាប់ :
  - + រថយន្តដឹកអ្នកដំណើរទុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី
- **ប័ណ្ណពណ៌ខៀវខ្ចី** ប្រើសំរាប់ :
  - + រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន

+ រ៉ឺម៉កសណ្តោង ដល់ ១០ តោន

+ រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេះ ដល់ ១៧សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ

- ប័ណ្ណពណ៌លឿងទុំ ប្រើសំរាប់ :

+ រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន

+ រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន

- ប័ណ្ណពណ៌ក្រហមនិងពណ៌លឿងខ្ចី ប្រើសំរាប់ :

+ រថយន្តដឹកទំនិញលើសពី ២០ តោន

+ រ៉ឺម៉កសណ្តោងលើសពី ២០ តោន

- ប័ណ្ណពណ៌បៃតងនិងពណ៌ត្រួយចេក ប្រើសំរាប់ :

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេះ ដល់ ២៤សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ

- ប័ណ្ណពណ៌លឿងទុំនិងពណ៌ផ្កាឈូក ប្រើសំរាប់ :

+ រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេះ ដល់ ២៤សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ

- ប័ណ្ណពណ៌ទឹកខៀវនិងពណ៌ផ្ទៃមេឃ ប្រើសំរាប់ :

+ រថយន្តទេសចរណ៍កម្លាំងលើសពី ២៤សេះ ឡើងទៅ

## ២. ប័ណ្ណរាងត្រីកោណ :

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។ នៅកណ្តាលប័ណ្ណមានលេខ "២០០៧" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៧" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" រាងត្រីកោណ ពណ៌ត្រួយចេក និង ពណ៌ទឹកប៊ិច មានសរសេរចំនួនប្រាក់ពន្ធ ខាងក្រោមចំនួនប្រាក់ពន្ធ មានសរសេរលេខរៀងនៃប័ណ្ណនីមួយៗ ។ ដោយឡែកប័ណ្ណរាងត្រីកោណពណ៌ស ពុំមានសរសេរចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងត្រីកោណនេះមាន ៣ ពណ៌គឺ :

- ប័ណ្ណពណ៌ត្រួយចេក ប្រើសំរាប់ :

+ ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ សម³

- ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :

+ ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ៧០សម³ ទៅ ១២៥ សម³

- ប័ណ្ណពណ៌ស ប្រើសំរាប់ :

+ ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ១២៥ សម³ ឡើងទៅ ដែលមានទឹកប្រាក់ពន្ធចំនួន ៧.៥០០ រៀល

+ ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ ដែលមានទឹកប្រាក់ពន្ធចំនួន ១៥.០០០ រៀល

៣. ប័ណ្ណរាងអដ្ឋកោណ :

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។ នៅកណ្តាលប័ណ្ណមានលេខ "២០០៧" សញ្ញារូបហង្ស និងមានអក្សរ "ប័ណ្ណបង់ពន្ធជលយាន" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៧" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធជលយាន" មានលេខរៀងនៃប័ណ្ណនីមួយៗ។ ប័ណ្ណរាងអដ្ឋកោណនេះ ពុំមានសរសេរចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងអដ្ឋកោណនេះមាន ៣ ពណ៌គឺ :

- ប័ណ្ណពណ៌ត្រួយចេក ប្រើសំរាប់ :
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០៛ ដល់ ៧០.០០០៛
- ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០៛ ដល់ ៥០០.០០០៛
- ប័ណ្ណពណ៌ស ប្រើសំរាប់ :
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០៛ ដល់ ១.២០០.០០០៛

ប្រការ៩.- ដោយឡែក សំរាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះរថយន្តដឹកទំនិញ និង រ៉ឺម៉ក-សណ្តោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុបដែលរួមមានទម្ងន់រថយន្តទទេ និងទម្ងន់ផ្ទុក(ទំនិញ-មនុស្ស)។

- ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០.០០០៛ ។
- រីឯរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០.០០០៛ ។
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ ។
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ ។
- និងរ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០.០០០៛ ។

ប្រការ១០.- យានយន្តគ្រប់ប្រភេទដែលមានប័ណ្ណសំគាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ គ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៦ ហើយបានលក់ទៅឱ្យអ្នកផ្សេង ក្នុងករណីនេះត្រូវកំណត់ឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៦ និងបង់ប្រាក់ពិន័យស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៧ ។

ប្រការ១១.- ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ នេះតទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដង ស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណាដែលមិនបានមកបង់ពន្ធសំរាប់ឆ្នាំ ២០០៧ ដូចបានកំណត់ក្នុងប្រការ ១ ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និង ត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធខេត្ត-ក្រុង នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ ២០០៧ នេះ ។

ការត្រួតពិនិត្យនឹងត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយក្នុងភូមិ ឃុំ សង្កាត់ .... និង ទីចំណតនានា ។

ប្រការ១២.- ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប "
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..................សហវ.....

## តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់ ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

( តារាងឧបសម្ព័ន្ធទី I )

ភ្ជាប់ជាមួយប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឯកតា: រៀល

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | អត្រាប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង | |
|---|---|---|
| - រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្តទទេនិងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)] : | | |
| + ដល់ ៣ តោន | 150 000 | |
| + លើសពី ៣ តោន ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (រ៉ឺម៉កនិងទំនិញ) : | | |
| + ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥ កៅអី | 250 000 | |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥ កៅអី | 200 000 | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | 150 000 | |
| - រថយន្តទេសចរណ៍ គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| + កម្លាំងដល់ ៩ សេះ | 100 000 | 80 000 |
| + កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ | 150 000 | 100 000 |
| + កម្លាំងលើសពី ១២ សេះ ដល់ ១៧ សេះ | 250 000 | 180 000 |
| + កម្លាំងលើសពី ១៧ សេះ ដល់ ២៤ សេះ | 800 000 | 600 000 |

| | |
|---|---|
| + កម្លាំងលើសពី ២៤ សេះ ឡើងទៅ | 1 000 000 |
| - ត្រាក់ទ័រកម្លាំង ៨២ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល | 50 000 |
| - ត្រាក់ទ័រកម្លាំង ៦៥ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល | 40 000 |
| - ត្រាក់ទ័រកម្លាំង ៣៥ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល | 30 000 |
| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **កំរិតប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង** |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ ស.ម³ | 3 000 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ៧០ ស.ម³ ដល់ ១២៥ ស.ម³ | 4 500 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ ស.ម³ ឡើងទៅ | 7 500 |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ | 15 000 |
| **<u>ជលយាន ឬជលយានយន្តផ្លូវទន្លេ</u> :** | |
| - ជលយានដឹកទំនិញ : | |
| + ដល់ ៣ តោន | 50 000 |
| + លើសពី ៣ តោន ដល់ ១០ តោន | 100 000 |
| + លើសពី ១០ តោន ដល់ ២០ តោន | 200 000 |
| +លើសពី ២០ តោន | 300 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 200 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ | 300 000 |
| - កប៉ាល់សណ្តោងមានកំលាំងដល់ ៥០ សេះ | 20 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 30 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 50 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១៥០ សេះ ដល់ ២០០ សេះ | 60 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២០០ សេះ ដល់ ២៥០ សេះ | 180 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ឡើងទៅ | 300 000 |
| - កាណូតនេសាទមានកំលាំងដល់ ៥០ សេះ | 10 000 |
| - កាណូតនេសាទមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 20 000 |
| - កាណូតនេសាទមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 30 000 |
| - ទូកម៉ាស៊ីនចំហៀង " ជើងបង្គង " | 10 000 |
| - អូប៊័រមានកំលាំងដល់ ២៥ សេះ | 150 000 |
| - អូប៊័រមានកំលាំងលើសពី ២៥ សេះ ដល់ ៤០ សេះ | 200 000 |
| - អូប៊័រមានកំលាំងលើសពី ៤០ សេះ ដល់ ៨០ សេះ | 300 000 |
| - អូប៊័រមានកំលាំងលើសពី ៨០ សេះ ដល់ ២០០ សេះ | 400 000 |

| | |
|---|---|
| - អូប៉រមានកំលាំងលើសពី ២០០ សេះ ឡើងទៅ | 500 000 |
| **ជលយាន ឬជលយានយន្តផ្លូវសមុទ្រ** : | |
| - ទូកដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| - ទូកដឹកអ្នកដំណើរបណ្តោយពី ២១ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 150 000 |
| - ទូកដឹកទំនិញដល់ ១០០ តោន | 200 000 |
| - ទូកនេសាទដែលមានកំលាំងសេះដល់ ៩ សេះ | 10 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ១០ សេះ ដល់ ២០ សេះ | 15 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ២១ សេះ ដល់ ៤០ សេះ | 25 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ៤១ សេះ ដល់ ៨០ សេះ | 50 000 |
| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **កំរិតប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង** |
| - ទូកនេសាទដែលមានកំលាំងសេះពី ៨១ សេះ ដល់ ១៥០ សេះ | 70 000 |
| - ទូកនេសាទដែលមានកំលាំងសេះពី ១៥១ សេះ ឡើងទៅ | 100 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២ សេះ | 10 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ១៣ សេះ ដល់ ៥០ សេះ | 20 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ៥១ សេះ ឡើងទៅ | 50 000 |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានដល់ ១.០០០ តោន | 300 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១.០០០ តោន ដល់ ២.០០០ តោន | 750 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០ តោន ឡើងទៅ | 1 200 000 |
| - កប៉ាល់នេសាទមានកំលាំងដល់ ១៥០ សេះ | 300 000 |
| - កប៉ាល់នេសាទមានកំលាំងលើសពី ១៥០ សេះ ដល់ ២៥០ សេះ | 400 000 |
| - កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 600 000 |
| - កប៉ាល់នេសាទមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | 1 200 000 |
| - កប៉ាល់សណ្តោងមានកំលាំងដល់ ២៥០ សេះ | 200 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 400 000 |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | 600 000 |

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ................. សហវ.........

# ឧបសម្ព័ន្ធកំណត់កំលាំងសេះរបស់រថយន្តទេសចរណ៍
(តារាងឧបសម្ព័ន្ធទី II)

ភ្ជាប់ជាមួយប្រកាសលេខ ១៥០ សហវ.ប្រក ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

| ល.រ | រថយន្តទេសចរណ៍ដែលប្រើប្រាស់ថាមពលសាំង ឬ មាហ្សូត | ចំនួន CC "វ៉ូលូម" | កំលាំងគិតជាសេះ | ប្រាក់ពន្ធត្រូវបង់ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | គិតពីឆ្នាំផលិត ដល់ ៥ឆ្នាំ | គិតពីឆ្នាំផលិត លើសពី ៥ឆ្នាំ | |
| ១ | រថយន្តទេសចរណ៍ | ដល់ ១ ៥០០ CC | ដល់ ៩ សេះ | ១០០ ០០០ | ៨០ ០០០ | និយមហៅ ១.៥ |
| ២ | រថយន្តទេសចរណ៍ | លើសពី ១ ៥០០ CC ដល់ ២ ០០០ CC | លើសពី ៩ សេះ ដល់ ១២ សេះ | ១៥០ ០០០ | ១០០ ០០០ | និយមហៅ ១.៦ ដល់ ២ |
| ៣ | រថយន្តទេសចរណ៍ | លើសពី ២ ០០០ CC ដល់ ២ ៥០០ CC | លើសពី ១២ សេះ ដល់ ១៧ សេះ | ២៥០ ០០០ | ១៨០ ០០០ | និយមហៅ ២.២ ដល់ ២.៥ |
| ៤ | រថយន្តទេសចរណ៍ | លើសពី ២ ៥០០ CC ដល់ ៤ ០០០ CC | លើសពី ១៧ សេះ ដល់ ២៤ សេះ | ៨០០ ០០០ | ៦០០ ០០០ | និយមហៅ ៣ ដល់ ៤ |
| ៥ | រថយន្តទេសចរណ៍ | លើសពី ៤ ០០០ CC ឡើងទៅ | លើសពី ២៤ សេះ ឡើងទៅ | ១ ០០០ ០០០ | | និយមហៅ លើសពី ៤ |

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់